**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ: ០៨
ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ២០០៤
**សាលដីកា**
លេខ: ១៩៩
ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ................ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក ............... ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

-កញ្ញា .................

**តំណាងមហាអយ្យការ**

-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា ៩៨(ឈ) ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៨៧ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ រវាង:

- ដើមចោទឈ្មោះ លសវណ ចុងបណ្តឹងសាទុក្ខ ភេទប្រុស អាយុ ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរពេទ្យយោធាទីលំនៅផ្ទះលេខ ៧ ផ្លូវលេខ ៣៨០ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

- និងចុងចម្លើយ ឈ្មោះ ឈសគនរ ដើមបណ្តឹងសាទុក្ខ ភេទស្រី អាយុ ៤៨ឆ្នាំ ជាតិខ្មែរមុខរបរពាណិជ្ជករ ទីលំនៅផ្ទះលេខ ២៦ ផ្លូវលេខ ០៦ សង្កាត់បឹងកក់ ២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

មានមេធាវី លោក ...............

**អំពីវិវាទៈ** ប្តឹងទាមទារប្រាក់

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ០៨ ចុះថ្ងៃទី១៣ខែ មករា ឆ្នាំ ២០០៤ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ២០៤ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៣ របស់អ្នកស្រី ឈសគនរ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣០(ង) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍លើត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

- តាមពាក្យបណ្តឹង ចុះថ្ងៃទី២៧-០៥-២០០២ និងចម្លើយនៅពេលផ្សះផ្សា ពេលស៊ើបអង្កេតរបស់ដើមចោទឈ្មោះ លសវណ ថាប្តឹងទាមទារប្រាក់ចំនួន ៣៥.០០០ដុល្លាអាមេរិក ទាមទារជម្ងឺចិត្ត២៥០០០ដុល្លាអាមេរិក ទាមទារ

ការប្រាក់តាមច្បាប់ ស៊ុំរឹបអូសទ្រព្យសម្បត្តិ ដីឡូត៍លេខ ២៨ ផ្ទះ‌វ ៦០៦ សង្កាត់បឹងកេងកង២ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ សុំដាក់គុកបង្ខំរូបរាងកាយចុងចម្លើយឈ្មោះ ឈសគនរ និងប្តីឈ្មោះកាំង សារិនដើម្បីជានាសំណង ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ ១៩ (ក) ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលសម្រេចៈ

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១០-០៦-២០០២ របស់ឈ្មោះ លសវណ ទុកជាត្រឹមត្រូវតាមទម្រង់និង គតិច្បាប់ ។

២- ហាមឃាត់ឈ្មោះ ឈសគនរ និងប្តីឈ្មោះ កាំង សារិន មិនឱ្យលក់ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិឬធ្វើអំណោយអ្នកដទៃនូវផ្ទះលេខ ២៦ ផ្លូវលេខ ៦០៦ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលខ៨៨៥៣ ចុះថ្ងៃទី១៩-០៣-១៩៩២ និងដីដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ BX VII ១៥០ ដែលមានទំហំ ៧៣៧៥ម²នៅភូមិក្រាំងស្វាយ ឃុំព្រែកអំពិល ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានព្រំប្រទល់ ខាងជើងទល់នឹង ម៉ក់ ឈុនហ៊ាង, ខាងត្បូងទល់នឹងស៊ីម យឿន ផ្លូវជាតិលេខ២ ខាងកើតទល់នឹង ឡុង កាន, កែ កាន, ខាងលិចទល់នឹង កែ កាន ជាបណ្តោះអាសន្នសិន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តីចប់ជាស្ថាពរ ។

៣- បង្គាប់ឱ្យឈ្មោះ ឈសគនរ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន១៨០០រៀលរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល ប្រាក់នេះដើមបណ្តឹងបានបង់រួចហើយ ។

៤- គូភាគីណាមិនសុខចិត្តនិងដីកាសម្រេចនេះ មានសិទ្ធិប្តឹងទាស់រយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីដីកាសម្រេចនេះ ។

បានឃើញ ដីកាសម្រេចតាមពាក្យសុំ លេខ ៣២ (ក) ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលសម្រេចៈ

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី១២-៨-២០០២ របស់ឈ្មោះលីសុវណ្ណទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២- ហាមឃាត់មិនឱ្យឈ្មោះ ឈសគនរ និងប្តីឈ្មោះ កាំង សារិន ជួល លក់ខ្ចីបញ្ចាំផ្ទេរសិទ្ធិ ឬធ្វើអំណោយដល់អ្នកដទៃនូវ ដីឡូតិ៍លេខ២៨ មានទំហំ ៥៨៥០០ម² ផ្លូវ៦០៦ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានសេចក្តីសម្រេច របស់សាលាក្រុងភ្នំពេញ លេខ ១៥៨៥ ធ.កស ចុះថ្ងៃទី ០៩-៥-១៩៩៦ ជាបណ្តោះអាសន្នសិន រង់ចាំតុលាការសម្រេច ដល់អង្គសេចក្តីចប់ជាស្ថាពរ ។

៣- បង្គាប់ឱ្យឈ្មោះ ឈសគនរ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល ប្រាក់នេះដើមបណ្តឹងបានបង់រួចហើយ ។

៤- គូភាគីណាមិនសុខចិត្តនឹងដីកាសម្រេចនេះ មានសិទ្ធិប្តឹងទាស់រយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួល បណ្តឹងពីដីកាសម្រេចនេះ ។

បានឃើញបណ្តឹទាស់ របស់លោក .............. មេធាវីតំណាងឱ្យអ្នកស្រី ឈសគនរ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេច តាមពាក្យសុំលេខ ៣២(ក) ចុះថ្ងៃទី ១៣-០៨-២០០២ របស់តុលាការក្រុងភ្នំពេញ លើគ្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ ៣៦ ប្រ(ក) ចុះថ្ងៃទី០៩ខែកញ្ញា ឆ្នាំ ២០០២របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅៈ

១- ទទួលពាក្យបណ្តឹង អ្នកស្រី ឈសគនរ មានមេធាវី .............. ជាតំណាង ចុះថ្ងៃទី២២-៨-២០០២ និងចម្លើយតវ៉ា នៅពេលសវនាការទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងច្បាប់ ។

២-បដិសេធដីកាតាមពាក្យសុំលេខ ១៩(ក) ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញចោល តាមការសុំមិនសុខចិត្តរបស់លោក លសវណ ។

៣-តម្កល់ដីកាសម្រេចតាមពាក្យសុំលេខ៣២(ក) ចុះថ្ងៃទី ១៣-៨-២០០២ របស់តុលាការក្រុង ភ្នំពេញ ទុកជាបានការដូចដើម ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៤០០០៛ ដាក់ថវិការដ្ឋ និងចំណាយផ្សេងៗ ។

៥-ដីកាសម្រេចនេះ មានអានុភាពសម្រេចភ្លាមៗ ទោះបីជាប់បណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៦- ដីកាសម្រេចសេចក្តីចំពោះមុខមេធាវី .............. តំណាងអ្នកស្រី ឈសគនរ ចំពោះមុខលោក លសវណ បើកផ្លូវឧទ្ធរណ៍២ខែ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៥៨(ក) ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០០២ របស់លោក.............. មេធាវីតំណាងឱ្យអ្នកស្រី ឈសគនរ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចកិច្ចការប្រញាប់លេខ ៣៦ប្រ(ក) ចុះថ្ងៃទី០៩ខែ កញ្ញា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ លើគ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៣០ (ង) ចុះថ្ងៃទី១៧ខែមីនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៧-០៩-២០០២ របស់លោកមេធាវី .............. ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់ដីកាសម្រេចកិច្ចការប្រញាប់លេខ ៣៦ប្រ(ក) ចុះថ្ងៃទី ០៩-០៩-២០០២ របស់តុលាការក្រុងភ្នំពេញទុកជាបានការ ។

៣- សម្រេចកាត់យកប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ចំនួន ២៥៥០រៀល រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ៥.០០០រៀល និង ចំណាយលើអាជ្ញាធរ តុលាការចំនួន៥០០០រៀល សរុប ១៣០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទមេធាវីដើមចោទ ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ២០៤ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០៣ របស់អ្នកស្រី ឈសគនរ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៣០(ង) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ របស់សាលឧទ្ធរណ៍លើត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៧០ ចុះថ្ងៃទី១១ ខែធ្នូឆ្នាំ ២០០៣ របស់តុលាការកំពូលដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលបណ្តឹងសាទុក្ខលេខ ២០៤ ចុះថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ ២០០៣ របស់ភាគីដើមបណ្តឹងសាទុក្ខឈ្មោះ ឈសគនរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៣០(ង) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-បញ្ជូនសណ្តុំរឿងរដ្ឋប្បវេណីលេខ ២៨២ប្រ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្តី ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក លសវណ បានបង់នៅតុលាការកំពូល ចំនួន១៩.០០០រៀល គឺ

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥០០០រៀល សរុប ១៩.០០០រៀល.

ហើយតម្រូវឱ្យអ្នកស្រី ឈសគនរ សងប្រាក់ចំនួន ១៩.០០០រៀល នេះ ទៅលោក លសវណ

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៣ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៥១(ក) ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ លសវណ មានលក្ខណៈត្រឹមត្រូវ តាមទម្រង់ និងគតិ ច្បាប់ ។

២- លិខិតផ្ទេរសិទ្ធិរបស់អ្នកស្រី ឈសគនរ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ឱ្យមកឈ្មោះ ............... ជាមេធាវីតំណាង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- បដិសេធពាក្យសុំពន្យាពេលសវនាការរបស់មេធាវី .............. ជាតំណាងឱ្យអ្នកស្រីឈសគនរ ចោល ។

៤- បង្គាប់ឱ្យអ្នកស្រី ឈសគនរ និងប្តីឈ្មោះ កាំង សារិន ជាចុងចម្លើយ មានលោក .............. ជាមេធាវី និងជាតំណាង សងប្រាក់ជំពាក់ចំនួន ៣៥០០០ដុល្លាអាមេរិក តាមកិច្ចសន្យាជំពាក់ប្រាក់មួយ ចុះថ្ងៃទី ១៣-១១-២០០០ និង ការប្រាក់តាមច្បាប់៥% លើទឹកប្រាក់ដើមចំនួន ៣៥០០០ដុល្លាអាមេរិក ( បីម៉ឺនប្រាំពាន់ដុល្លាអាមេរិក )គិតចាប់ពីថ្ងៃទី១៣ ខែវិច្ឆកា ឆ្នាំ២០០០ រហូតសងប្រាក់គ្រប់ និងជម្ងឺចិត្តចំនួន១០.០០០ដុល្លាអាមេរិក ឱ្យទៅលោកលសវណ ជាដើមចោទ សុំជម្ងឺចិត្តលើសពីនេះលើកចោល ដោយធ្វើការទូទាត់ជាមួយការប្រាក់ដែលបានទូទាត់រួចហើយចំនួន ៧៧០០ដុល្លាអាមេរិក ។ បើគ្មានប្រាក់សងទេ ស៊ីរឹបអូសទ្រព្យសម្បត្តិ ដែលមានដីឡូត៍ លេខ ២៨ ផ្ទះ ៦០៦ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ដែលមានទំហំ ៥៨៥០០ម² ដែលមានសេចក្តីសម្រេចរបស់សាលាក្រុងភ្នំពេញ លេខ ១៥៨៥ ធ.ត.ស ចុះថ្ងៃទី ០៩-៥-១៩៩៦ ដែលបានរឹបអូសឃាត់ជាបណ្តោះអាសន្នរួចហើយ តាមដីកាសម្រេចកិច្ចការប្រញាប់លេខ ៣៦ប្រ.ក ចុះថ្ងៃទី ០៩-៩-០២ តម្កល់តាមដីកាសម្រេចតាមពាក្យសុំលេខ ៣២(ក) ចុះថ្ងៃទី ១៨-៨-២០០២ របស់តុលាការក្រុងភ្នំពេញ ។ បើរឹងរូសមិនអនុវត្តតាមសេចក្តី សម្រេចនៃសាលក្រម អនុញ្ញាតិឱ្យដាក់គុកបង្ខំរូបកាយ ទារសំណងតាមមាត្រា ១ ២ ៣ ២២, ២៥ ៥៦ ៥៧ ៥៩ នៃក្រិត្យច្បាប់កិច្ចសន្យាលេខ៣៨ និងមាត្រា ១២៧, ១២៨ ១២៩ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥- ឱ្យចុងចម្លើយ បង់ពន្ធសមាមាត្រ មួយភាគរយលើចំនួនទឹកប្រាក់ ដែលត្រូវសងទៅដើមចោទ ប្រាក់នេះ ឱ្យដើមចោទបង់ជាមុន និង ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ដែលបានកាត់យកពី ប្រាក់ប្រដាប់ក្តីរបស់ដើមចោទ ដាក់ថវិការដ្ឋ និង ចំណាយផ្សេងៗ រួចហើយ តម្រូវឱ្យចុងចម្លើយសងប្រាក់ពន្ធសមាមាត្រ និងប្រាក់ប្រដាប់ក្តីទាំងនេះ ទៅដើមចោទវិញ នៅពេលសាលក្រមស្ថាពរ ។

៦- សាលក្រមនេះជំនុំជំរះ ចំពោះមុខដើមចោទ និង កំបាំងមុខមេធាវី និង អ្នកស្រីឈសគនរ សម្រេចបើកផ្លូវប្តឹងទាស់រយៈពេល១៥ថ្ងៃ ចាប់គិតពីពេលទទួលដំណឹងនិងរយៈពេលបណ្តឹងឧទ្ធរណ៍កំណត់ ២ខែចាប់គិតពីថ្ងៃ ផុតបណ្តឹងទាស់ ។

បានឃើញ បណ្តឹងទាស់លេខ ៦៣(ក) ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ២០០២ របស់លោក ............... មេធាវីការពារឱ្យចុងចម្លើយប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៥១(ក) ចុះថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ ២០០២ របស់តុលាការក្រុងភ្នំពេញ លើត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៦៤(ក) ចុះថ្ងៃទី២៨ ខែវិច្ឆិកាឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងតវ៉ាទាស់លេខ៦៣ ចុះថ្ងៃទី ២៤-១០-០២ ចំពោះសាលក្រមកំបាំងមុខលេខ ៥១(ក) ចុះថ្ងៃទី ២៦-៩-២០០២ របស់មេធាវី ............... ជាតំណាងរបស់អ្នកស្រី ឈសគនរ ទុកជាត្រឹម ត្រូវតាមច្បាប់ ។

២- បដិសេធសាលក្រមកំបាំងមុខលេខ៥១(ក)ចុះថ្ងៃទី២៦-៩-២០០២របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចទី៣ ត្រង់ ( បង្គាប់ឱ្យអ្នកស្រី ឈសគនរ និងប្តីឈ្មោះ កាំង សារិន មានមេធាវី ............... ជាតំណាងសងប្រាក់ចំនួន ៣៥.០០០ដុល្លាអាមេរិក ( បីម៉ឺនប្រាំពាន់ដុល្លាអាមេរិក) តាមកិច្ចសន្យាចុះថ្ងៃទី ១៣-១១-២០០០ និងការប្រាក់ ៥%

លើប្រាក់ដើម ៣៥,០០០ដុល្លាអាមេរិក ឱ្យទៅលោក លសវណ គិតចាប់ពីថ្ងៃទី ១៣-១១-២០០០ រហូតដល់សងប្រាក់គ្រប់ចោលចេញ) ហើយសម្រេចសេចក្តីជាថ្មីថា ( បង្គាប់ឱ្យអ្នកស្រីឈសគនរ និងប្តីឈ្មោះកាំង សារិន សងប្រាក់ដើមចំនួន២៩.៩០០ ដុល្លាអាមេរិក( ពីរម៉ឺនប្រាំបួនពាន់ប្រាំបួនរយដុល្លាអាមេរិក )និងការប្រាក់៥%លើប្រាក់ដើម ២៩៩០០ដុល្លាអាមេរិក គិតពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០១ រហូតសងប្រាក់គ្រប់ ដោយកាត់ប្រាក់បានសងរួចហើយតាមបង្កាន់ដៃ ចុះថ្ងៃទី ៣០-៣-២០០១ ចំនួន ១.១០០ ដុល្លាអាមេរិក ចុះថ្ងៃទី ០៣-៧-២០០១ ចំនួន ២,០០០ដុល្លាអាមេរិក និង ចុះថ្ងៃទី ២៨-៣-២០០២ ចំនួន ២០០០ដុល្លាមេរិក សរុប ៥១០០ដុល្លាអាមេរិក រួចដកចេញពីប្រាក់ដើម ៣៥.០០០ដុល្លាអាមេរិក-៥១០០ដុល្លាអាមេរិក=២៩៩០០ដុល្លាអាមេរិក។ ចំនួនដ៏ទៃទៀតនៃសាលក្រមកំបាំងមុខលេខ៥១(ក) ចុះថ្ងៃទី ២៦-៩-២០០២ រក្សាទុកនៅដូចដើម (មាត្រ ២២-២៣-៣០-៥៨-៥៩ នៃក្រិត្យច្បាប់ ស្តីពីកិច្ចសន្យាលេខ ៣៨ )

៣- សាលក្រមនេះ សម្រេចសេចក្តី និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវី ............... តំណាង អ្នកស្រីឈសគនរ ដើមបណ្តឹងទាស់ និងចំពោះមុខលោក លសវណ ចុងបណ្តឹងទាស់ បើកផ្លូវប្តឹងតវ៉ាឧទ្ធរណ៍កំណត់២ខែ គិតចាប់ពីថ្ងៃទីសម្រេចសេចក្តីនេះ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៧២(ក) ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០២ របស់ មេធាវីលោក............... តំណាងឱ្យអ្នកស្រី ឈសគនរ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៦៤(ក) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០០២ របស់តុលាការក្រុងភ្នំពេញ លើត្រង់ចំណុចសេចក្តីសម្រេចទាំងមូល និង បណ្តឹងឧទ្ធរណ៍លេខ០២(ក)ចុះថ្ងៃទី១០ខែមករាឆ្នាំ២០០៣ របស់លោកលីសុវណ្ណមិនសុខចិត្តលើត្រង់ចំណុចសេចក្តីសម្រេចទាមទារប្រាក់ដើម ៣៥.០០០ដុល្លាអាមេរិក និង សុំបន្ថែមជម្ងឺចិត្តនៅចំណុចទី៣ ក្រៅពីនេះសុំរក្សាទុកដូចសេចក្តីសម្រេចដដែល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦០(ឈ)ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០-១២-២០០២ របស់លោក មេធាវី ............... ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០-០១-២០០៣ របស់ឈ្មោះ លសវណ ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៦៤ (ក) ចុះថ្ងៃទី២៨-១១-២០០២ និង លេខ ៥១(ក) ចុះថ្ងៃទី ២៦-៩-២០០២ របស់តុលាការក្រុងភ្នំពេញចោល ជាអសារបង់ ។

៤- បង្គាប់ឱ្យចុងចម្លើយឈ្មោះ ឈសគនរ និង ប្តីឈ្មោះ កាំង សារិន សងប្រាក់ដើមចំនួន ២៩២០៦,២១ ដុល្លាអាមេរិក( ពីរម៉ឺនប្រាំបួនពាន់ពីរយប្រាំមួយដុល្លានិងម្ភៃមួយសេន) និងការប្រាក់៥% ក្នុងមួយឆ្នាំលើប្រាក់ដើមចំនួន ២៩២០៦, ២១ ដុល្លានេះ គិតចាប់ពីថ្ងៃទី ២៨-៣-២០០២ រហូតដល់ថ្ងៃទូទាត់បំណុលរួច និងជម្ងឺចិត្តចំនួន ១០.០០០ដុល្លាអាមេរិក (មួយម៉ឺនដុល្លា) ។ សំណូមពរលើសពីនេះ បដិសេធចោល។

ក្នុងករណីគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិមានដីឡូត៍លេខ២៨ ផ្លូវលេខ៦០៦ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ដែលបានឃាត់ទុកជាបណ្ដោះអាសន្ន តាមដីកាសម្រេចកិច្ចការប្រញាប់លេខ៣៦ប្រ(ក) ចុះថ្ងៃទី០៩ខែកញ្ញា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ លក់ឡាយឡុងដើម្បីជានាសំណង ។ ក្នុងករណី លក់ឡាយឡុងដីឡូត៍ខាងលើសងបំណុលមិនគ្រប់ទេ ត្រូវរឹបអូសទ្រព្យសម្បត្តិដទៃទៀត លក់ឡាយឡុងដើម្បី ជានាសំណងបន្ថែមទៀត។ ក្នុងករណីរឹងរូស ត្រូវដាក់គុកបង្ខំរូបកាយតាមច្បាប់ ស្ដីពីការអនុវត្តន៍សាលក្រមរដ្ឋប្បវេណី ។

៥- កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ២៦,០០០៛ ដែលឈ្មោះ លសវណ បានបង់សម្រាប់ដើមបណ្ដឹងទាំងពីរួចហើយ ក្នុងម្នាក់១១៣០០០រៀល គឺពន្ធចុះបញ្ជីក្ដីនិងពន្ធហ្នឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ ។ កាលបើផុតបណ្ដឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះ ឈសគនរ សងប្រាក់ ២៦.០០០រៀល ទៅឱ្យ ឈ្មោះ លសវណ វិញនិងបង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ ១% លើប្រាក់ដែលត្រូវសងនិងជម្ងឺចិត្ត ។

៦- សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី១៨-៤-២០០៣ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២៤-៤-២០០៣ ចំពោះមុខដើមចោទ កំបាំងមុខក្នុងចម្លើយ បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងទាស់លេខ៥៩ ចុះថ្ងៃទី២០ខែ ឧសភាឆ្នាំ២០០៣ របស់អ្នកស្រី ឈសគនរ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦០(ឈ) ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៩៨(ឈ) ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្ដីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី២០-០៥-២០០៣ របស់ឈ្មោះ ឈសគនរ ទុកជាត្រឹម ត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ៦០(ឈ) ចុះថ្ងៃទី ២៤-៤-២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ ដោយគ្រាន់តែកែប្រែសំណងជំងឺចិត្តពី១០.០០០USD(មួយម៉ឺនដុល្លាអាមេរិក)មកនៅត្រឹម៨០០០USD (ប្រាំបីពាន់ដុល្លាអាមេរិក)វិញ ។ ចំណុចផ្សេងពីនេះ រក្សាទុកជាបានការដដែល ។

៣- សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ០៨-០៧-២០០៣ ចំពោះមុខគូក្ដីនិងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩-០៧-២០០៣ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ តែចាត់ទុកជាចំពោះមុខ។

បើកផ្លូវប្ដឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៣ របស់អ្នកស្រី ឈិនសុគន្ធារី( ពាក្យបណ្ដឹងសាទុក្ខ ចុះថ្ងៃទី១០-១០-២០០៣) មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩៨(ឈ) ចុះថ្ងៃទី០៩ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ ២០០៤ របស់ អ្នកស្រី ឈសគនរ

បានឃើញ សារណាតប ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់លោក លសវណ

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

- បណ្ដឹងសាទុក្ខរបស់ចុងចម្លើយស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

- សាលដីការដ្ឋប្បវេណីលេខ ៩៨(ឈ)ចុះថ្ងៃទី០៩-០៧-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់អ្នកស្រី ឈសគនរ បានឆ្លើយថា: មកពីខ្លួនប្ដឹងមិនសុខចិត្តនេះពីសាលាឧទ្ធរណ៍កាត់ក្ដីមិនត្រឹមត្រូវ តាមពិតលុយនេះ មិនមែនជាលុយចងការខ្ចីអ្វីទេ គឺជាលុយដែលដាក់ទុនរកស៊ីក្រពើជាមួយគ្នា ដូចនេះខ្លួនសុំសងតែលុយដើមដែលដាក់ហ៊ុនរកស៊ីចូលគ្នាតែប៉ុណ្ណោះ ហើយខ្លួនក៏បានចែកចំណេញឱ្យគាត់ដែរ ប៉ុន្តែសាលាឧទ្ធរណ៍បែរជាកាត់ក្ដីឱ្យខ្លួនសងទាំងដើម ទាំងការប្រាក់ និងជំងឺចិត្តទៀត ខ្លួនសូមបដិសេធទាងស្រុង ។

ដូចនេះខ្លួន សូមសងតែប្រាក់ដើម ដាក់ហ៊ុនចូលគ្នារកស៊ីទេ ។

បានស្ដាប់ចម្លើយរបស់លោក លសវណ បានឆ្លើយថា ខ្លួនមិនអាចចោលបានទេ ចំពោះរឿងការប្រាក់ ប៉ុន្តែរឿងជំងឺចិត្តនោះ ខ្លួនអាចបន្ធូឱ្យបានខ្លះបាន។ ចំពោះនបញ្ហាដែលផាត់ថា ដាក់ហ៊ុនរកស៊ីចូលគ្នានោះ ពុំត្រឹមត្រូវទាល់តែសោះ តាមការពិតលុយនេះ គឺជាលុយដែលគាត់ខ្ចីខ្លួនទេ ហើយខ្លួនសូមចោលលុយឱ្យតាម សាលាឧទ្ធរណ៍កាត់ក្ដីចុះ ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីលោក ............... ការពារឱ្យចុងចម្លើយបញ្ជាក់ថា

ការរកស៊ីដាក់ហ៊ុនចូលគ្នានេះ ហើយបានចំណេញចែកគ្នា រហូតដល់មានការរកស៊ីខាតបង់នោះទើបដើមចោទបានបង្ខំឱ្យកូនក្ដីខ្លួន ធ្វើជាកិច្ចសន្យាឡើងដោយគ្មានការប្រាក់ទេ។ ប៉ុន្តែមកដល់តុលាការលោកបែរជាទាមទារយកការប្រាក់ទៅវិញ ហើយសាលាឧទ្ធរណ៍ក៏បានសម្រេចដោយឱ្យកូនក្ដីខ្លួនសងមានការប្រាក់ ហើយថែមទាំងទាមទារប្រាក់ជំងឺចិត្តទៀត ។ ដូចនេះ កូនក្ដីរបស់ខ្លួន សូមសងតែប្រាក់ដើម ដាក់ហ៊ុនចូលគ្នាតែប៉ុណ្ណោះ ។

សូមតុលាការកំពូល មេត្តាបដិសេធសាលដីកាសាលាឧទ្ធរណ៍ ចោលទាំងមូល ។

- ក្រោយពីបានស្ដាប់របាយការណ៍ចៅក្រមរបាយការណ៍

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្ដាប់ចម្លើយរបស់គូភាគី និង សេចក្ដីសន្និដ្ឋានរបស់មេធាវីក្នុងចម្លើយ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៣ របស់អ្នកស្រីឈសគនរ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ចុងចម្លើយពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន ៣៥.០០០ ដុល្លាអាមេរិក តាមកិច្ចសន្យាចុះថ្ងៃទី ១៣-១១-២០០០ ប្រាកដមែន ។ ប៉ុន្តែចុងចម្លើយបានសងការប្រាក់ចំនួន ៧ លើក គិតមកត្រឹមថ្ងៃទី ២៨-៣-២០០២ សរុប៨២០០ ដុល្លាអាមេរិក។ បើតាមមាត្រា ៦០ នៃក្រិត្យច្បាប់លេខ ៣៨ក្រចក្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅតិច្ចសន្យា គិតមកត្រឹម កាលបរិច្ឆេទខាងលើ ដើមចោទត្រូវទទួលបានតែ២៤០៦,២១ដុល្លាអាមេរិកប៉ុណ្ណោះ ។ ដូច្នេះ ដើមចោទបានទទួលការប្រាក់ដែលខុសច្បាប់ ត្រូវគិតជាប្រាក់ ដើមវិញ គឺ ៨.២០០ដុល្លា-២៤០៦,២១ដុល្លា = ៥៧៩៣,៧៩ដុល្លាអាមេរិក ។ ដូចនេះ ចុងចម្លើយនៅមានកាតព្វកិច្ចសងទៅដើមចោទវិញតែចំនួន ៣៥.០០០ដុល្លា-៥៧៩៣៧៩ដុល្លា = ២៩.២០៦,២១ ដុល្លាអាមេរិក ។

- យល់ឃើញថា នាសវនាការនេះ ចុងចម្លើយ និង មេធាវីចុងចម្លើយ សំណូមពរសុំឱ្យលុបចោល ការប្រាក់ និងជម្ងឺចិត្ត ប៉ុន្តែដើមចោទបានបដិសេធ ហើយព្រមបញ្ចុះការប្រាក់ចំនួន២០០០ដុល្លាអាមេរិក តុលាការ កំពូលគប្បីកែប្រែសំណងជម្ងឺចិត្តតាមការឯកភាពពីដើមចោទ ។

-យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ ៩៨ (ឈ) ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី១០ខែ តុលា ឆ្នាំ ២០០៣ របស់អ្នកស្រី ឈឹន សុគន្ធារីទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៩៨ (ឈ) ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុច ស្តីពីសំណងជម្ងឺចិត្ត ត្រូវកែប្រែពី ៨.០០០ដុល្លាអាមេរិក មកជា៦.០០០ដុល្លាអាមេរិកវិញ ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០រៀល ដែលដើមចោទ បានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

ចំណាយលើការប្រគល់ដីកាកោះ ចំនួន១៥០០០រៀល សរុប ១៩០០០ រៀល ។

- បង្គាប់ឱ្យចុងចម្លើយសងប្រាក់១៩០០០រៀល ទៅដើមចោទវិញ និងបង្គាប់ឱ្យចុងចម្លើយបង់ ពន្ធសមាមាត្រ ១% លើប្រាក់ដែលត្រូវសងទៅដើមចោទ ។

៤-សាលដីការនេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៤ខែ កញ្ញា ឆ្នាំ ២០០៤ ។